**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្តល់ប្រាក់រង្វាន់ចំពោះជ័យលាភីជនពិការ ក្នុងការប្រកួតប្រជែងមុខជំនាញ ការប្រកួតកីឡាសៀវស្សាល់អូឡាំពិក និងប្រាក់ឧបត្ថម្ភសម្រាប់គ្រូបង្វឹក គ្រូបង្វឹកជំនួយ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៩/០១០ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩១២/០០៧ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ
- បានឃើញអនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការបង្កើតគណៈកម្មាធិការជាតិអូឡាំពិកសម្រាប់ជនពិការ
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា/.



www.pheakdeylaw.com

- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាសកម្មភាពជនពិការ
- បានឃើញអនុក្រឹត្យលេខ៥៨ អនក្រ.បកចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះ មានគោលបំណងលើកកម្ពស់សិទ្ធិជនពិការនិងលើកទឹកចិត្តក្នុងការចូលរួមប្រកួតប្រជែងមុខជំនាញនិងការប្រកួតកីឡាស្មើស្មាល់អូឡាំពិកជាលក្ខណៈជាតិនិងអន្តរជាតិ។

**មាត្រា២ .-**

អនុក្រឹត្យនេះ មានគោលដៅផ្តល់ប្រាក់រង្វាន់ចំពោះជ័យលាភីជាជនពិការគ្រប់ប្រភេទ និងប្រាក់ឧបត្ថម្ភចំពោះគ្រូបង្វឹក គ្រូបង្វឹកជំនួយ អ្នកដឹកនាំក្រុម និងអ្នកថែទាំដែលចូលរួមក្នុងការប្រកួតប្រជែងមុខជំនាញនិងការប្រកួតកីឡាស្មើស្មាល់អូឡាំពិកជាលក្ខណៈជាតិនិងអន្តរជាតិ។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះរាល់ការប្រកួតប្រជែងរបស់ជនពិការជាលក្ខណៈជាតិនិងអន្តរជាតិ ដែលប្រារព្ធធ្វើឡើងនៅក្នុងឬក្រៅប្រទេស និងត្រូវបានអនុញ្ញាតឱ្យទៅចូលរួមជាផ្លូវការដោយរាជរដ្ឋាភិបាល តាមរយៈក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាឬក្រុមប្រឹក្សាសកម្មភាពជនពិការ។

**មាត្រា៤ .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចតទៅ៖

ជនពិការ សំដៅដល់ជនទាំងឡាយណាដែលខ្វះខាត បាត់បង់ ខូចខាតសរីរាង្គណាមួយ ឬសតិបញ្ញា បណ្តាលឱ្យមានការរំខានដល់ជីវភាពរស់នៅឬសកម្មភាពនានាប្រចាំថ្ងៃ ដូចជាជនពិការរាងកាយ ពិការភ្នែក ពិការក្នុងការស្តាប់ ពិការសតិបញ្ញា មនសិការវិកល និងប្រភេទពិការផ្សេងៗទៀតដែលនាំឱ្យមានលក្ខណៈមិនប្រក្រតី។

ជ័យលាភី សំដៅដល់ជនពិការជាឯកត្តជនឬជាក្រុម ដែលទទួលបានមេដាយក្នុងការប្រកួតជាលក្ខណៈជាតិនិងអន្តរជាតិ នៅក្នុងប្រទេសឬក្រៅប្រទេស។

អត្តពលិកពិការខ្សោយសតិបញ្ញា សំដៅដល់ជនទាំងឡាយណាដែលមានផលវិបាកក្នុងការចងចាំ ភ្លេចច្រើនឬមិនអាចធ្វើដូចមនុស្សដទៃទៀតដែលមានអាយុដំណាលគ្នា។

គ្រូបង្វឹក សំដៅដល់អ្នកមានជំនាញជាបុរសឬនារី ដែលត្រូវចាត់ឱ្យបង្វឹកត្រៀមមុខជំនាញសម្រាប់ការប្រកួតប្រជែង។/



www.pheakdeylaw.com

**គ្រូបង្វឹកជំនួយ** សំដៅដល់អ្នកជំនួយការគ្រូបង្វឹក ដែលត្រូវចាត់ឲ្យបង្វឹកត្រៀមលើមុខជំនាញសម្រាប់ការប្រកួតប្រជែង។

**អ្នកដឹកនាំក្រុម** សំដៅដល់អ្នកដែលទទួលបានការចាត់តាំងជាផ្លូវការ ក្នុងការដឹកនាំក្រុមចូលរួមប្រកួតប្រជែង ជាលក្ខណៈជាតិនិងអន្តរជាតិ។

**អ្នកថែទាំជនពិការ** សំដៅដល់អ្នកដែលទទួលបានការចាត់តាំងជាផ្លូវការដើម្បីថែទាំនិងសម្របសម្រួលដល់ភាពងាយស្រួលសម្រាប់ជនពិការ ក្នុងការធ្វើដំណើរ ស្នាក់នៅ និងសកម្មភាពប្រចាំថ្ងៃផ្សេងៗទៀត ក្នុងដំណើរការនៃការប្រកួតប្រជែង។

**ការប្រកួតប្រជែងជំនាញជាលក្ខណៈជាតិ** សំដៅដល់ការប្រកួតប្រជែងលើចំណេះដឹង ចំណេះធ្វើ ការបង្ហាញសមត្ថភាព លើវិញ្ញាសាជំនាញនានា ការប្រកួតអាចជាលក្ខណៈឯកត្តបុគ្គល ឬជាក្រុម ដែលរៀបចំដោយក្រសួង ស្ថាប័នពាក់ព័ន្ធវិស័យពិការភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងមានការចូលរួមពីជនពិការទូទាំងប្រទេស។

**ការប្រកួតប្រជែងជំនាញជាលក្ខណៈអន្តរជាតិ** សំដៅដល់ការប្រកួតប្រជែងលើចំណេះដឹង ចំណេះធ្វើ ការបង្ហាញសមត្ថភាពលើវិញ្ញាសាជំនាញនានា ការប្រកួតអាចជាលក្ខណៈឯកត្តបុគ្គលឬជាក្រុម ដែលកំណត់ដោយគណៈកម្មការរៀបចំការប្រកួតជាលក្ខណៈអន្តរជាតិនៅក្នុងប្រទេសឬក្រៅប្រទេស ដោយមានការចូលរួមពីប្រទេសនានាក្នុងតំបន់អាស៊ាន អាស៊ីប៉ាស៊ីហ្វិក និងពិភពលោក។

**ការប្រកួតកីឡាស្នើស្បាល់អូឡាំពិកជាលក្ខណៈអន្តរជាតិ** សំដៅដល់ការរៀបចំប្រកួតកីឡា សម្រាប់តែជនពិការខ្សោយសតិបញ្ញាដែលមានអាយុចាប់ពី៨ឆ្នាំឡើងទៅ ដែលការប្រកួតនេះ មានការបែងចែកទៅតាមកម្រិតអាយុ បញ្ញា និងភេទ និងរៀបចំជាលក្ខណៈអនុតំបន់ទន្លេមេគង្គ អាស៊ីប៉ាស៊ីហ្វិក និងពិភពលោក។

## ជំពូកទី២
## ការផ្ដល់ប្រាក់រង្វាន់និងប្រាក់ឧបត្ថម្ភ

**មាត្រា៥ .-**

ប្រាក់រង្វាន់ចំពោះជនពិការដែលដណ្ដើមបានជ័យលាភី ទទួលបានមេដាយមាស មេដាយប្រាក់ ឬមេដាយសំរិទ្ធក្នុងការប្រកួតប្រជែងមុខជំនាញ ត្រូវកំណត់ដូចខាងក្រោម៖

| កម្រិត | ប្រភេទមេដាយ | | |
|---|---|---|---|
| | មេដាយមាស | មេដាយប្រាក់ | មេដាយសំរិទ្ធ |
| កម្រិតជាតិ | ១០ ០០០ ០០០រៀល | ៥ ០០០ ០០០រៀល | ៣ ០០០ ០០០រៀល |
| កម្រិតអាស៊ាន | ២០ ០០០ ០០០រៀល | ១៥ ០០០ ០០០រៀល | ១០ ០០០ ០០០រៀល |
| កម្រិតអាស៊ីប៉ាស៊ីហ្វិក | ៣០ ០០០ ០០០រៀល | ២០ ០០០ ០០០រៀល | ១៦ ០០០ ០០០រៀល |
| កម្រិតពិភពលោក | ៤០ ០០០ ០០០រៀល | ៣០ ០០០ ០០០រៀល | ២០ ០០០ ០០០រៀល |



www.pheakdeylaw.com

- គ្រូបង្វឹក ត្រូវទទួលបានប្រាក់ឧបត្ថម្ភស្មើនឹង៧០% នៃប្រាក់រង្វាន់ជ័យលាភីដែលទទួលបានចំណាត់ថ្នាក់មេដាយខ្ពស់ជាងគេ ក្នុងវិញ្ញាសាប្រកួតក្នុងក្រុមដែលខ្លួនទទួលបន្ទុកបង្វឹក។
- គ្រូបង្វឹកជំនួយម្នាក់ៗ ត្រូវទទួលបានប្រាក់ឧបត្ថម្ភចំនួន៥០% នៃប្រាក់ឧបត្ថម្ភសម្រាប់គ្រូបង្វឹក។
- អ្នកដឹកនាំ ត្រូវទទួលបានប្រាក់ឧបត្ថម្ភចំនួន៤០% នៃប្រាក់ឧបត្ថម្ភសម្រាប់គ្រូបង្វឹក។
- អ្នកថែទាំជនពិការម្នាក់ៗ ត្រូវទទួលបានប្រាក់ឧបត្ថម្ភចំនួន២០% នៃប្រាក់ឧបត្ថម្ភសម្រាប់គ្រូបង្វឹក។

**មាត្រា៦ .-**

ប្រាក់រង្វាន់ចំពោះជនពិការដែលដណ្តើមបានជ័យលាភី ទទួលបានមេដាយមាស មេដាយប្រាក់ ឬមេដាយសំរឹទ្ធ ក្នុងការប្រកួតកីឡាស្មៀស្សាល់អូឡាំពិក ត្រូវកំណត់ដូចខាងក្រោម៖

| កម្រិត | ប្រភេទមេដាយ | | |
|---|---|---|---|
| | មេដាយមាស | មេដាយប្រាក់ | មេដាយសំរឹទ្ធ |
| អនុតំបន់ទន្លេមេគង្គ | ១០ ០០០ ០០០រៀល | ៧ ៥០០ ០០០រៀល | ៤ ០០០ ០០០រៀល |
| អាស៊ីប៉ាស៊ីហ្វិក រដូវក្តៅឬរដូវរងា | ២០ ០០០ ០០០រៀល | ១០ ០០០ ០០០រៀល | ៦ ០០០ ០០០រៀល |
| ពិភពលោក រដូវក្តៅឬរដូវរងា | ៣០ ០០០ ០០០រៀល | ២០ ០០០ ០០០រៀល | ១៦ ០០០ ០០០រៀល |

- គ្រូបង្វឹក ត្រូវបានប្រាក់ឧបត្ថម្ភស្មើនឹងប្រាក់រង្វាន់ជ័យលាភីដែលទទួលបានចំណាត់ថ្នាក់មេដាយខ្ពស់ជាងគេ ក្នុងវិញ្ញាសាប្រកួតក្នុងក្រុម ដែលខ្លួនទទួលបន្ទុកបង្វឹក។
- គ្រូបង្វឹកជំនួយម្នាក់ៗ ត្រូវទទួលបានប្រាក់ឧបត្ថម្ភចំនួន៧០% នៃប្រាក់ឧបត្ថម្ភសម្រាប់គ្រូបង្វឹក។
- អ្នកដឹកនាំ ត្រូវទទួលបានប្រាក់ឧបត្ថម្ភចំនួន៤០% នៃប្រាក់ឧបត្ថម្ភសម្រាប់គ្រូបង្វឹក ។
- អ្នកថែទាំជនពិការម្នាក់ៗ ត្រូវទទួលបានប្រាក់ឧបត្ថម្ភចំនួន២០% នៃប្រាក់ឧបត្ថម្ភសម្រាប់គ្រូបង្វឹក។

ចំពោះជ័យលាភីជាក្រុម ប្រាក់រង្វាន់ត្រូវបានផ្តល់ជូនសមាជិកក្រុមម្នាក់ៗ ទៅតាមកម្រិតចំណាត់ថ្នាក់ដែលក្រុមទទួលបាន។

**មាត្រា៧ .-**

ការផ្តល់ប្រាក់រង្វាន់និងប្រាក់ឧបត្ថម្ភដូចមានកំណត់ក្នុងអនុក្រឹត្យនេះ ជាបន្ទុករបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

## ជំពូកទី៣

## អវសានប្បញ្ញត្តិ

**មាត្រា៨ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។



www.pheakdeylaw.com

**មាត្រា៩ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០១៦

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន**
**និងយុវនីតិសម្បទា**

**វង សូត**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



www.pheakdeylaw.com